CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១០ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងបើកអាជីវកម្មបន្ថែមទៀត

*បារកន្លែងសប្បាយសម្រាប់គ្រួសារនិងហាងធ្វើក្រចកមិនត្រូវបានរាប់បញ្ចូលក្នុងការបើកជាថ្មីទេ*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - បន្ទាប់ពីការពិនិត្យនូវគោលការណ៍ណែនាំថ្មីរបស់រដ្ឋនិងទិន្នន័យសុខភាពក្នុងតំបន់ទីក្រុងឡុងប៊ិចនៅថ្ងៃនេះបានប្រកាសបើកអាជីវកម្មបន្ថែមទៀតដូចជាកន្លែងហាត់ប្រាណកន្លែងបោះជំរំសារមន្ទីរនិងសណ្ឋាគារចាប់ពីថ្ងៃសុក្រទី ១២ ខែមិថុនា។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ការបើកឡើងវិញទាំងនេះគឺជាជំហានដ៏សំខាន់ឆ្ពោះទៅមុខក្នុងការធ្វើឲ្យសេដ្ឋកិច្ចក្នុងតំបន់យើងមានភាពរស់រវើកឡើងវិញប៉ុន្តែ COVID-19 នៅតែជាភាពអាសន្នផ្នែកសុខភាពសាធារណៈ។ ចំពោះមនុស្សគ្រប់គ្នានៅក្នុងសហគមន៍របស់យើង សូមចងចាំថាត្រូវពាក់របាំងមុខនិងលាងដៃអោយបានញឹកញាប់ដើម្បីការពារសុវត្ថិភាពរបស់សហគមន៍យើង។"

បទបញ្ជាសុខភាពដែលបានធ្វើវិសោធនកម្មនិងពិធីសារសុវត្ថិភាពដែលអាចអនុវត្តបាននឹងមកដល់ហើយរួមបញ្ចូលទាំងបញ្ជីអាជីវកម្មពេញលេញដែលអាចបើកនៅថ្ងៃទី ១២ ខែមិថុនារួមមាន៖

- កន្លែងហាត់ប្រាណ
- កីឡាអាជីពដោយគ្មានទស្សនិកជនទៅមើលផ្ទាល់
- កម្មវិធីជុំរុំសំរាប់យុវជន
- សារមន្ទីរ វិចិត្រសាល និងជលវប្បដ្ឋាន (អាងចិញ្ចឹមត្រី)
- កន្លែងបោះជំរុំ ឧទ្យានសម្រាប់ចត RV និងការកំសាន្តខាងក្រៅ
- ផលិតកម្មតន្ត្រីខ្សែភាពយន្តនិងទូរទស្សន៍
- សណ្ឋាគារ ផ្ទះសំណាក់ និងផ្ទះជួលរយៈពេលខ្លីសម្រាប់វិស័យទេសចរណ៍និងការធ្វើដំណើរផ្ទាល់ខ្លួន

ខាងក្រោមនៅតែបិទ៖

- ហាងធ្វើក្រចក
- ហាងសាក់លើស្បែក
- ហាងស្ប៉ានិងធ្វើម៉ាស្សា
- ហាងស្រាបៀរ រោងម៉ាស៊ីនផលិតស្រាបៀរ បារ ហាងស្រា និងហាងស្រាដែលមិនបម្រើអាហារ
- រោងកុន
- មជ្ឈមណ្ឌលកម្សាន្តជាលក្ខណៈគ្រួសារ (ឧទាហរណ៍កន្លែងលេងល្បែងអេកឡិចសម្រាប់កុមារ និងកន្លែងបោះប៊ូល)
- ការទៅមើលការសម្តែងល្ខោន
- កន្លែងកម្សាន្តនិងសាលប្រគុំតន្ត្រី
- ស្ពាត
- សែវៀន
- កន្លែងលេងល្បែង
- ពិធីបុណ្យ

មន្ទីរសុខាភិបាលនិងសេវាប្រជាជនរបស់ទីក្រុងនឹងតាមដានទិន្នន័យអំពីរោគរាតត្បាតនៅសប្តាហ៍ក្រោយដើម្បីកំណត់ថាតើត្រូវបើកអាជីវកម្មណាបន្ថែមទៀតដែលត្រូវបានអនុញ្ញាតដោយអភិបាលរដ្ឋ

Gavin Newsom ជាផ្នែកមួយនៃការបើកឡើងវិញដំណាក់កាលទី ៣ ដូចជាបារនិងមជ្ឈមណ្ឌលកម្សាន្ត ជាលក្ខណៈគ្រួសារ។

៧០ ភាគរយនៃចំណតរថយន្តនៅឯឆ្នេរសមុទ្រត្រូវបានបើកកាលពីចុងសប្តាហ៍មុន។ កន្លែងចតរថយន្ត ដែលមិនត្រូវបានអនុញ្ញាតិឱ្យចតត្រូវបានសម្គាល់ដោយសញ្ញា "មិនអាចចតបាន(No Parking)" ដើម្បី អនុញ្ញាតឱ្យមានការអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នា។ ស្លាកសញ្ញាត្រូវបានដាក់នៅច្រកចូលនិង នៅស្ថានីយ៍បង់ប្រាក់នីមួយៗ។ អេក្រង់នៅតាមស្ថានីយ៍បង់ប្រាក់ក៏ណែនាំឱ្យអ្នកប្រើប្រាស់កុំចតនៅតូប ដែលមិនត្រូវបានអនុញ្ញាតឱ្យចត។ តូបទាំងនេះមិនអាចរកបាននៅតាមស្ថានីយ៍នីមួយៗនិងនៅលើកម្ម វិធី Passport ទូរស័ព្ទចល័តសម្រាប់រកកន្លែងចតបានទេ។

ដើម្បីគាំទ្រដល់ប្រតិបត្តិការចំណតនឹងមានបុគ្គលិកស្ថិតនៅចំណតរថយន្តនីមួយៗរៀងរាល់ថ្ងៃសុក្រ ដល់ថ្ងៃអាទិត្យក្នុងអំឡុងពេលពីរសប្តាហ៍ខាងមុខដើម្បីផ្តល់ការណែនាំ។ ផ្ទៃលើម៉ាស៊ីនដែលត្រូវបានប៉ះ ជាញឹកញាប់នឹងត្រូវសម្អាតជាប្រចាំ។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និង យោងទៅតាមអំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការ ប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។ បទបញ្ជានេះមានប្រសិទ្ធភាពភ្លា មៗនៅថ្ងៃទី ២៧ ខែឧសភាឆ្នាំ ២០២០ ហើយនឹងបន្តរហូតដល់បទបញ្ជានេះត្រូវបានពន្យារពេលដក ហូតវិញឬកែប្រែជាលាយលក្ខណ៍អក្សរដោយមន្ត្រីសុខាភិបាល។

បទបញ្ជាសុខភាពដែលត្រូវបានធ្វើបច្ចុប្បន្នភាពនឹងត្រូវតម្រឹមនឹងផែនទីបង្ហាញផ្លូវភាពរឹងប៉ឹងរបស់ខោន ធីនិងរដ្ឋកាលីហ្វ័រញ៉ា។ ម្ចាស់អាជីវកម្មត្រូវបានលើកទឹកចិត្តឱ្យពិនិត្យមើលគោលការណ៍ណែនាំរបស់រដ្ឋ មុនពេលដែលបទបញ្ជាសុខភាពឡុងប៊ិចដែលបានធ្វើវិសោធនកម្មនាពេលខាងមុខនេះចេញ។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បី ការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយ តាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #